**របាយការណ៍**

**ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល**

**សន្និសីទសារព័ត៌មានស្តីពី “ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្ត”**

ទីស្តីការគណៈរដ្ឋមន្ត្រី, ថ្ងៃព្រហស្បតិ៍ ទី៣០ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៨៖៣០នាទីព្រឹក

- ខ្ញុំព្រះករុណា ទូលព្រះបង្គំ សូមលំឱនកាយក្រាបថ្វាយបង្គំ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រមទាំងព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ***ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***
- សូមក្រាបថ្វាយបង្គំ **ព្រះករុណាព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ***ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***
- សូមគោរព **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***
- សូមគោរព **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា

  ***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***
- សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

  ***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***
- សូមគោរព **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល

  ***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

- សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***
- សូមគោរព សម្តេច ទ្រង់ ឯកឧត្តមនាយឧត្តមសេនីយ៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលកំពុងទស្សនាសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តកណ្តាល" ***ជាទីមេត្រី!***

តាងនាមឱ្យថ្នាក់ដឹកនាំរដ្ឋបាលខេត្ត កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែងដោយបានមកចូលរួមជាវាគ្មិនក្នុងសន្និសីទសារព័ត៌មាន នាឱកាសនេះ។ ខ្ញុំក៏សូមគោរពថ្លៃងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តកណ្តាល" ដែលបានផ្តល់ឱកាសឱ្យរូបខ្ញុំជាលើកទី២ ក្នុងនាមអភិបាល នៃគណៈអភិបាលខេត្តកណ្តាល ដើម្បីទូលថ្វាយ និងជម្រាបជូនអំពីវឌ្ឍនភាព និងសមិទ្ធផលនានាដែលរដ្ឋបាលខេត្តសម្រេចបាននាពេលកន្លងមក។ ជាមួយគ្នានេះ ខ្ញុំក៏សូមអរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមក្នុងសន្និសីទនេះ។

ជាបឋម ខ្ញុំបាទសូមអនុញ្ញាតសម្តែងនូវការគោរពដឹងគុណ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាអគ្គមហារដ្ឋបុរសដែលមានទេពកោសល្យបំផុតប្រកបដោយគតិបណ្ឌិត និងជាស្ថាបនិកមគ្គុទេសន៍ឯក ប្រតិបត្តិករនយោបាយឈ្នះ-ឈ្នះ ដោយបានផ្តើមចេញពីការយកអាយុជីវិត សាច់ស្រស់ ឈាមស្រស់ធ្វើជាដើមទុនដើម្បីសង្គ្រោះអាយុជីវិតរបស់ប្រជាពលរដ្ឋរាប់លាននាក់យ៉ាងអង់អាចក្លាហានពីរបបប៉ុលពត និងបានដាក់ចេញគោលនយោបាយស្តារសេដ្ឋកិច្ច សង្គម ពីកំទេចផេះផង់ ឈានទៅរកការរីកចម្រើននូវផ្នែកសេដ្ឋកិច្ច នាំមកនូវការអភិវឌ្ឍឥតឈប់ឈរ មានស្ថិរភាពនយោបាយ មានសន្តិភាពពិតប្រាកដ ធ្វើឱ្យប្រជាពលរដ្ឋរស់នៅដោយភាពសុខសាន្ត ដែលមិនធ្លាប់មានក្នុងរយៈពេល ៥០០ឆ្នាំចុងក្រោយ នៃប្រវត្តិសាស្ត្រកម្ពុជា។ **<u>សូមអរគុណសន្តិភាព!</u>**

ជាមួយគ្នានេះ ក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ក្នុងនាមជាប្រធានគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺ-១៩ បានខិតខំប្រឹងប្រែងប្រកបដោយភាពបុរេសកម្ម ក្នុងការជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋរាប់លាននាក់ពីគ្រោះមរណៈនៃជំងឺដ៏កាចសាហាវនេះ ព្រមទាំងអាចរក្សាបានលំនឹងជីវភាពប្រជាជន រក្សាបានកំណើនសេដ្ឋកិច្ច រក្សាបានស្ថិរភាព សន្តិសុខ សុវត្ថិភាពសង្គមរឹងមាំ។ ប្រការនេះ

ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ នូវសមត្ថភាពរបស់កម្ពុជាក្នុងការគ្រប់គ្រងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានល្អប្រសើរជាងបណ្តាប្រទេសជាច្រើន ទាំងក្នុងកម្រិតតំបន់ និងសកលលោក ព្រមទាំងការសម្រេចបាននូវភាពស៊ាំសហគមន៍ពេញលេញ និងរឹងមាំ ដែលជួយធានានូវសុវត្ថិភាព និងសុខភាពសាធារណៈសម្រាប់ប្រជាជនកម្ពុជា តាមរយៈការផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមអភិក្រមផ្ការីក និងចាក់ស្រោច ដោយឥតគិតថ្លៃ មិនប្រកាន់និន្នាការនយោបាយ ពូជសាសន៍ និងពណ៌សម្បុរ។

ទន្ទឹមនេះ ស្ថិតក្នុងបរិការណ៍នៃវិបត្តិអតិផរណាសេដ្ឋកិច្ចពិភពលោក **សម្តេចអគ្គមហាសេនាតេជោនាយករដ្ឋមន្ត្រី** ក៏បានដឹកនាំប្រទេសគ្រប់គ្រងស្ថានការណ៍បានយ៉ាងល្អប្រសើរ ទ្រង់ទ្រង់ស្ថានភាពសេដ្ឋកិច្ចមិនឱ្យធ្លាក់ចុះខ្លាំង ដោយដាក់ចេញអភិក្រមប្រតិបត្តិដែលមានភាពប្រាកដនិយម និងអាចអនុវត្តបាន ព្រមទាំងបានប្រែក្លាយពីការគំរាមកំហែងទៅជាឱកាសសម្រាប់ការកែទម្រង់នៅក្នុងប្រទេស សំដៅឆ្ពោះសម្រេចបានគោលដៅនៃការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យរបស់ប្រទេសបានយ៉ាងល្អបំផុត។

យើងខ្ញុំក៏មានមោទកភាពយ៉ាងក្រៃលែង ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ក្នុងការសម្របសម្រួលដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលបានអនុម័ត និងកត់សម្គាល់នូវបញ្ជីឯកសារសមិទ្ធផល ជាង១០០ឯកសារ ដើម្បីជាមគ្គុទេសក៍សម្រាប់សកម្មភាព និងសហប្រតិបត្តិការរបស់អាស៊ាន នាឆ្នាំខាងមុខបន្តទៀត ដែលនេះគឺជាជោគជ័យយ៉ាងត្រចះត្រចង់ជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ក្នុងការបំពេញតួនាទីជាប្រធានអាស៊ានប្តូរវេនក្នុងឆ្នាំ២០២២កន្លងទៅ ដែលបានលើកកម្ពស់តួនាទី និងកិត្យានុភាពរបស់កម្ពុជាយើងទាំងនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ។

ផ្អែកតាមសមិទ្ធផលជាច្រើន ដែលបាននិងកំពុងកកើតឡើង នៅក្រោមម្លប់សន្តិភាព យើងខ្ញុំទាំងអស់គ្នាប្តេជ្ញាចិត្តរួមគ្នា ថែរក្សារាល់សមិទ្ធិផលរបស់ជាតិឱ្យបានគង់វង្ស, កសាងប្រទេសជាតិឱ្យរីកចម្រើន ក្លាយជាប្រទេសជឿនលឿនមួយក្នុងតំបន់ ជាសង្គមប្រកបដោយអរិយធម៌ និងពុះពាររក្សាសន្តិភាពទោះបីត្រូវបង់ដោយតម្លៃណាក៏ដោយ និងសូមប្រឆាំងដាច់ខាតរាល់សកម្មភាពញុះញង់បំបែកបំបាក់ជាតិរបស់ក្រុមជនអគតិ ពូជក្បត់ជាតិ៣ជំនាន់។

រដ្ឋបាលខេត្តកណ្តាល សូមគាំទ្រយ៉ាងពេញទំហឹង **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** ជាបេក្ខជន នាយករដ្ឋមន្ត្រីសម្រាប់អាណត្តិទី៧ និងអាណត្តិក្រោយៗទៀត និង

គាំទ្រ**ឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត** ជាបេក្ខជន នាយករដ្ឋមន្ត្រីសម្រាប់ពេលអនាគត។

ជាបន្ត ខ្ញុំបាទសូមអនុញ្ញាតគោរពរាយការណ៍ អំពីភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តកណ្តាល ដូចខាងក្រោម ៖

I. **ស្ថានភាពទូទៅរបស់ខេត្ត ៖**

ខេត្តកណ្តាល ស្ថិតនៅភូមិភាគនិរតី នៃព្រះរាជាណាចក្រកម្ពុជា លាតសន្ធឹងតាមបណ្តោយដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ មានភូមិសាស្ត្រហ៊ុំព័ទ្ធជុំវិញរាជធានីភ្នំពេញ មានព្រំប្រទល់ខាងលិចទល់នឹងខេត្តកំពង់ស្ពឺ ខាងកើតទល់នឹងខេត្តព្រៃវែង ខាងជើងទល់នឹងខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម ខាងត្បូងទល់នឹងខេត្តតាកែវ និងខេត្តអានយ៉ាង ប្រទេសវៀតណាម មានខ្សែបន្ទាត់ព្រំដែនប្រវែង ២៩,៥គីឡូម៉ែត្រ។

- មានផ្ទៃដីសរុបមានទំហំ ៣២១.៤៦០ គ.ម$^{២}$
- មាន ១០ស្រុក ៣ក្រុង (ទើបបង្កើតថ្មីចំនួន២ គឺក្រុងអរិយក្សត្រ និងក្រុងសំពៅពូន) ១០១ឃុំ ២៦សង្កាត់ និង ១,០១០ភូមិ
- មានប្រជាជនសរុប ១,៣៤៨,៨៥១ នាក់ ស្មើនឹង ៣០៧,៧០៦ គ្រួសារ ក្នុងនោះអាយុ១៨ឆ្នាំឡើង មានចំនួន ៨៨៥,២៥៦ នាក់។
- បានតបណ្តាញអគ្គិសនីគ្របដណ្តប់លើភូមិទាំង ១០១០ភូមិ ស្មើនឹង ១០០%។
- ចំពោះការងារផ្គត់ផ្គង់ទឹកស្អាត នៅតាមបណ្តាក្រុង ស្រុក មានក្រុមហ៊ុនរដ្ឋ និងឯកជនមានអាជ្ញាបណ្ណចំនួន ៥៥មូលដ្ឋាន គ្របដណ្តប់ ១ ០១០ភូមិ។ បច្ចុប្បន្ន ការតបណ្តាញទឹកស្អាត បានចំនួន ៩៤៥ភូមិ និងមានខ្នងផ្ទះចំនួន ៦៦,១៨៦ខ្នងផ្ទះ ដែលមានទឹកស្អាតប្រើប្រាស់ ធៀបនឹងឆ្នាំ២០១៨ ខ្នងផ្ទះមានទឹកស្អាតប្រើប្រាស់មានចំនួន ១៥,០០០ ខ្នងផ្ទះ។ ខេត្តកណ្តាល ក៏មានរោងចក្រផលិតកម្មទឹកស្អាតក្រុងតាខ្មៅ ដែលមានតម្លៃប្រមាណ ៣០លានដុល្លារ មានសមត្ថភាពផលិតទឹកស្អាតបានជាង ៣ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ ដែលនឹងអាចផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋនៅក្រុងតាខ្មៅទាំងមូល និងជាយក្រុងតាខ្មៅ មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ នៅពេលរោងចក្រនេះបញ្ចប់ការសាងសង់នៅចុងឆ្នាំ២០២៤។

II. **សមិទ្ធិផលសំខាន់ៗសម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២៣)**

1) <u>ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព</u> ៖

ក្រោមការដឹកនាំ ចង្អុលបង្ហាញរបស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងតាមរយៈការអនុវត្តការងារប្រកបដោយភាពម៉ឺងម៉ាត់របស់គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ការចាត់តាំងអនុវត្តគោល

នយោបាយ ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព បានដំណើរការយ៉ាងសកម្មផុលផុស និងទទួលបានការចូលរួមគាំទ្រពីគ្រប់មជ្ឈដ្ឋាន ពិសេសមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល រួមជាមួយកម្លាំងប្រជាការពារ ដែលជាបង្អែកយ៉ាងរឹងមាំក្នុងការគ្រប់គ្រងស្ថានការណ៍សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពនៅមូលដ្ឋាន។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានធ្វើឱ្យបទល្មើសនានា មានការថយចុះ ជាក់ស្តែងក្នុងឆ្នាំ២០២២ បទល្មើសមានការថយចុះ **៧៨%** គួបផ្សំប្រតិបត្តិការបង្ក្រាបទទួលបានខ្ពស់រហូតដល់ **៩៦%** លើកលែងតែគ្រោះថ្នាក់ចរាចរណ៍ដែលមានការកើនឡើង ១៩លើក ស្មើនឹង១០%។

ជាមួយនឹងលទ្ធផលនៃការខិតខំប្រឹងប្រែងអនុវត្តការងាររបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ការប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព រដ្ឋបាលខេត្ត ទទួលបានលទ្ធផលគួរជាទីមោទនៈ ដោយឆ្នាំ២០២២ ក្នុងចំណោម ១២៧ឃុំ/សង្កាត់ទូទាំងខេត្ត ឃុំសង្កាត់ទទួលបានចំណាត់ថ្នាក់ប្រភេទលេខ១ មានចំនួន ១១៨ឃុំ/សង្កាត់, ចំណាត់ថ្នាក់ប្រភេទលេខ២ ចំនួន ៩ឃុំ/សង្កាត់ និងចំណាត់ថ្នាក់ប្រភេទលេខ៣ មិនមាន ធៀបនឹងឆ្នាំ២០១៨ ឃុំ សង្កាត់ ទទួលបានចំណាត់ថ្នាក់លេខ១ មានចំនួន ៥០ ឃុំ/សង្កាត់, ចំណាត់ថ្នាក់លេខ២ ចំនួន ៦៩ឃុំ/សង្កាត់ និងចំណាត់ថ្នាក់ប្រភេទលេខ៣ ចំនួន៨ ។

➢ **ការងារព្រំដែន៖** រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយតំបន់ព្រំដែន ឱ្យទៅជាតំបន់មានសន្តិសុខ និងការអភិវឌ្ឍ រួមជាមួយកិច្ចសហប្រតិបត្តិការល្អជាមួយខេត្តអានយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងស្មារតីលើកកម្ពស់ចំណងទំនាក់ទំនងសាមគ្គីភាព មិត្តភាព ប្រពៃណីល្អក្នុងនាមជាអ្នកជិតខាងល្អ រដ្ឋបាលខេត្តខេត្តសម្រេចបាននូវសមិទ្ធិផលជាច្រើននៅតាមខ្សែបន្ទាត់ព្រំដែន មានដូចខាងក្រោម ៖

- បានសាងសង់ជញ្ជាំងជើងទេរធ្វើពីបេតុងកម្ពស់៨ម៉ែត្រ ប្រវែង១០០ម៉ែត្រ សម្រាប់ការពារច្រាំង និងបង្គោលព្រំដែនលេខ ២៤៦/២ ស្ថិតក្នុងភូមិជ្រៃធំ សង្កាត់សំពៅពូន ក្រុងសំពៅពូន
- បានតម្រៀបបាវខ្សាច់ប្រភេទ Geo-Textile ចំនួន១,៩៥៦បាវ នៅតាមមាត់ច្រាំងបណ្តោយប្រមាណ ១០០ម៉ែត្រ សម្រាប់ការពារច្រាំង និងបង្គោលព្រំដែនលេខ ២៤៥/៤(១) ស្ថិតនៅសង្កាត់ព្រែកជ្រៃ ក្រុងសំពៅពូន។
- បានសាងសង់ប៉ុស្តិ៍នគរបាលចំនួន២១ប៉ុស្តិ៍ ដើម្បីការពារសន្តិសុខ សណ្តាប់ធ្នាប់ និងទប់ស្កាត់ បង្ក្រាបបទល្មើសនានា នៅតាមខ្សែបន្ទាត់ព្រំដែន។

- បានអភិវឌ្ឍន៍ និងកែលម្អសោភ័ណភាពប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងវត្តអារាមនៅតំបន់ព្រំដែន ដើម្បីទាក់ទាញទេសចរណ៍។

2) **ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

អនុវត្តតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) ដែលមានគោលបំណង "លើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការកែលម្អនូវដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកក្នុងការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង រដ្ឋបាលខេត្ត អនុវត្តសម្រេចបានយ៉ាងជោគជ័យតាមផែនការនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចខាងក្រោម ៖

- បានធ្វើសមាហរណកម្ម និងការរៀបចំបុគ្គលិកនៅតាមការិយាល័យ និងអង្គភាពនានាចំនួន ៧២២ នាក់ (ស្រី១៩៧នាក់) ក្នុងនោះមានមន្រ្តីជាប់កិច្ចសន្យាចំនួន ៣០នាក់ (ស្រី១២នាក់) ទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក។
- បានធ្វើការគ្រប់គ្រងដោយផ្ទាល់លើបុគ្គលិកសុខាភិបាល ចំនួន ១,៨០៩ នាក់(ស្រី ១,០៩២នាក់) ដែលត្រូវបានផ្ទេរមកឱ្យរដ្ឋបាលខេត្ត ជាអ្នកទទួលខុសត្រូវ និងចាត់ចែង។
- **ការងារផ្តល់សេវាសាធារណៈតាមអង្គភាពច្រកចេញចូលតែមួយ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធិភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលខេត្ត បាននិងកំពុងជម្រុញ និងគាំទ្រការផ្តល់សេវាសាធារណៈតាមរយៈយន្តការច្រកចេញចូលតែមួយខេត្ត, ការិយាល័យច្រកចេញចូលតែមួយក្រុងស្រុក និងយន្តការច្រកចេញចូលតែមួយឃុំសង្កាត់។ ក្នុងរយៈពេល៥ឆ្នាំនេះ អង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត បានផ្តល់សេវាជូនប្រជាពលរដ្ឋ សរុបចំនួន ១៥៦,៣៧៥ សេវា ទទួលបានចំណូលសរុប ២៩ប៊ីលាន ៥៦៧លាន ៤៨១ពាន់ ៥០០រៀល។
- ជាមួយគ្នានេះ តាមរយៈអនុក្រឹត្យលេខ ១២០អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដែលជាយន្តការថ្មីរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនទំហំទឹកប្រាក់ពី ២ លានដុល្លារ ដល់ ៥លានដុល្លារចុះក្រោម ដើម្បីផ្តល់ជូនរដ្ឋបាលខេត្តក្នុងការពិនិត្យសម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិ

យោគ គឺបានផ្តល់ភាពងាយស្រួលបន្ថែមទៀតដល់វិនិយោគិន ដែលមានបំណងធ្វើការវិនិយោគក្នុងមូលដ្ឋានខេត្តដែលមានទុនក្រោម ៥លានដុល្លារអាមេរិក អាចធ្វើការស្នើសុំធ្វើការវិនិយោគតាមរយៈអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត។ គិតមកទល់ពេលបច្ចុប្បន្ន គម្រោងវិនិយោគក្នុងសមត្ថកិច្ចរបស់អនុគណៈកម្មាធិការខេត្ត មានសរុបចំនួន ៦គម្រោង មានទុនវិនិយោគ ៩,៣០៩,២៧២ ដុល្លារ។

3) **<u>អំពីសេដ្ឋកិច្ចខេត្ត</u>**

ក្រោមម្លប់សន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាព និងតាមរយៈការជួយឧបត្ថម្ភគាំទ្ររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល ដឹកនាំដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងមូលដ្ឋានខេត្ត មានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងនោះ រយៈពេល៥ឆ្នាំ ២០១៨-២០២២ សេដ្ឋកិច្ចខេត្តកណ្តាល មានប្រមាណ ១១ប៊ីលាន ២៥២លាន ៦៥៥ពាន់រៀល បើគិតតាមថ្លៃបច្ចុប្បន្ននៅឆ្នាំ២០២១ កើនឡើង៤,៩% នៃសេដ្ឋកិច្ចជាតិ និង៤,៦% បើធៀបនឹងសេដ្ឋកិច្ចខេត្ត។

អនុវត្តតាមកំណែទម្រង់មុតស្រួចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣ដំណាក់កាលនាពេលកន្លងមក និងបានឈានចូលដំណាក់កាលទី៤ **"គណនេយ្យភាពសមិទ្ធកម្ម"** នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលខេត្ត បានជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឱ្យរីកចម្រើនប្រកបដោយចីរភាព សមធម៌ និងបរិយាប័ន្ន ក្នុងនោះ ៖

- ផលិតផលក្នុងស្រុកក្នុងឆ្នាំ២០២២ មានចំនួន ២ប៊ីលាន ៦៣៥លាន ៣០ពាន់ដុល្លារ បើធៀបនឹងឆ្នាំ២០១៨ គឺមាន ២ប៊ីលាន ៣៤៤លាន ៤០០ពាន់ ដុល្លារ។
- GDP សម្រាប់មនុស្សម្នាក់ៗ ក្នុងឆ្នាំ២០២២ មានចំនួន ២,០៦៤ ដុល្លារ បើធៀបនឹងឆ្នាំ២០១៨ មានចំនួន ១,៨៥៩.៥ដុល្លារ ដុល្លារ កើនឡើង ២០៤ ដុល្លារ។
- អត្រាគ្រួសារក្រីក្របានថយចុះពី ៥.៣៣ %ក្នុងឆ្នាំ២០១៨ មកនៅសល់ត្រឹម៣.៦៨ % ក្នុងឆ្នាំ២០២១។
- អត្រាអ្នកមានការងារក្នុងឆ្នាំ២០២២(អាយុ១៨ឆ្នាំដល់៦០ឆ្នាំ) មានចំនួន៧៧.៤%។

4) **<u>អំពីការគ្រប់គ្រងចំណូលចំណាយរបស់រដ្ឋបាលខេត្ត</u>**

ការគ្រោងផែនការហិរញ្ញវត្ថុសម្រាប់ការអនុវត្តថវិការបស់រដ្ឋបាលខេត្ត គឺត្រូវបានរៀបចំឡើងដោយគិតគូពីស្ថានភាព និងគ្រប់ទិដ្ឋភាពតម្រូវការនៃការអភិវឌ្ឍរបស់ខេត្ត។ ជាក់ស្តែងនៅក្នុងបរិបទនៃវិបត្តិជំងឺកូវីដ១៩ ថវិការបស់រដ្ឋបាលខេត្ត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកែសម្រួល សមស្រប សម្រាប់កិច្ច

អភិវឌ្ឍន៍ក្នុងមូលដ្ឋានខេត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ដែលត្រូវបានប្រសិទ្ធនាមជាថវិកា "វិត្តារកម្មចំគោលដៅ ដើម្បីមនុស្ស និងកំណើនសេដ្ឋកិច្ច" ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣។

គិតត្រឹមខែមីនា ឆ្នាំ២០២៣ ការអនុវត្តចំណូលរបស់ខេត្ត សម្រេចបាន១៤.៨១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។ ចំណូលសារពើពន្ធសម្រេចបាន ១៣.៥៨% និងចំណូលមិនមែនសារពើពន្ធសម្រេចបាន ២០.៦៤%។ ផ្អែកលើនិន្នាកានៃការអនុវត្តចំណូល ក្នុងរយៈពេល៣ខែដើមឆ្នាំ គួបផ្សំនឹងការងើបឡើងវិញនៃសកម្មភាពភាពសង្គម សេដ្ឋកិច្ច ការប្រមូលចំណូលក្នុងឆ្នាំ២០២៣ នឹងសម្រេចបាន ឬអាចប្រមូលបានលើសផែនការគ្រោងទុកក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។

ចំពោះការអនុវត្តចំណាយ សម្រេចបាន ១ប៊ីលាន ៨៤៨លានរៀល ស្មើនឹង ១.៣៨% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៣។

ជារួមចំណូល ចំណាយ របស់រដ្ឋបាលខេត្ត គឺមានស្ថានភាពល្អប្រសើរ ជាពិសេសការអនុវត្តចំណូលរបស់រដ្ឋបាលខេត្ត គឺមានការកើនឡើងលើសផែនការគ្រោងទុកនៃច្បាប់ហិរញ្ញវត្ថុក្នុងឆ្នាំនីមួយៗ ចាប់ពីឆ្នាំ២០១៨មក និងជាពិសេសនៅក្នុងវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២១ រហូតដល់ឆ្នាំ២០២២ ការអនុវត្តចំណូលរបស់រដ្ឋខេត្តក្នុងឆ្នាំ២០២២មានការកើនឡើងលើផែនការរហូតដល់ ១៩៥.៦១% នៃច្បាប់ហិរញ្ញវត្ថុ។

អាស្រ័យដោយការរៀបចំផែនការហិរញ្ញវត្ថុ មានសង្គតិភាពជាមួយផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត បានផ្តល់នូវកាលានុវត្តភាពដល់ខេត្ត ក្នុងការកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តបម្រើដល់ប្រយោជន៍សាធារណៈនៅទូទាំងខេត្ត តាមរយៈគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ អគាររដ្ឋបាល ការសាងសង់ស្ពាន សាលារៀន ។ល។ ជាក់ស្តែងគម្រោងអភិវឌ្ឍក្នុងឆ្នាំ២០១៨ មានថវិកាត្រឹមតែចំនួន ៥០ប៊ីលាន ៨៤២លាន ៥០០ពាន់រៀល , បានកើនដល់ ១៣៦ប៊ីលាន ៥៨០លាន ២០០ពាន់ រៀល ក្នុងឆ្នាំ២០២២ កើនចំនួន ៨៥ប៊ីលាន ៧៣៧លាន ៧០០ពាន់រៀល ស្មើនឹង ១៦៨.៦៣% នៃកញ្ចប់ថវិកាអភិវឌ្ឍន៍ឆ្នាំ២០១៨។ ចំនួនថវិកាគុណប្រយោជន៍ខេត្ត បានអនុញ្ញាតឱ្យរដ្ឋបាលខេត្តសម្រេចបាននូវសមិទ្ធផលជាច្រើន ដូចជា ការជួសជុលផ្លូវបេតុងអាមេ ២០៨ខ្សែ ប្រវែង ១៩៦គីឡូម៉ែត្រ និង៧២៩ម៉ែត្រ, ការដាក់បង្គោលភ្លើងបំភ្លឺសាធារណៈចំនួន ៧,៧០០បង្គោល, ការសាងសង់ប៉ុស្តិ៍នគរបាលរដ្ឋបាលចំនួន ១១កន្លែង, សាងសង់សាលារៀន ០៤ខ្នង ១៩បន្ទប់, សាងសង់អគារច្រកចេញចូលតែមួយសាលាស្រុក ៧អគារ, សាងសង់អគារសាលាឃុំ សង្កាត់ ចំនួន ៣៦កន្លែង, ការសាងសង់សួនកុមារ ១កន្លែង, រួមជាមួយការជួសជុលផ្លូវថ្មម៉ិច, ក្រួសក្រហម, ដីស, ស្ពានប្រឡាយ, ដាក់ប្រព័ន្ធលូ, សាងសង់បង្គន់អ

នាម័យសាធារណៈ, ស្ពាន, ទ្វារទឹក, ការរៀបចំការ៉ូឡាតាមសួនច្បារ និងផ្លូវថ្មើរជើងទីសាធារណៈ ជាដើម។

## 5) <u>វិស័យសាធារណការ និងដឹកជញ្ជូន</u>

**"មានផ្លូវ គឺមានក្តីសង្ឃឹម"** ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ បានចូលរួមចំណែកយ៉ាងសំខាន់ជម្រុញកំណើនសេដ្ឋកិច្ច ដែលជួយសម្រួលដល់ចរាចរណ៍ ការដឹកជញ្ជូនទំនិញ អ្នកដំណើរ ទេសចរណ៍ ព្រមទាំងកសិផល និងដំណាំកសិឧស្សាហកម្មផ្សេងៗជាច្រើនរបស់បងប្អូនប្រជាពលរដ្ឋ និងក្រុមហ៊ុនធុរកិច្ចនានា ទៅកាន់ទីផ្សារឱ្យកាន់តែឆាប់រហ័ស និងចំណាយតិច។ ក្នុងរយៈពេល៥ឆ្នាំនេះ សមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធជាចម្រើនបានលេចរូបរាងឡើងក្នុងទឹកដី ខេត្តកណ្តាល មានដូចជា៖

- ផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ មានប្រវែងជាង ១៨៧គីឡូម៉ែត្រ មាន៤គន្លង ក្រាលបេតុងកៅស៊ូ (AC) ឆ្លងកាត់ខេត្តកណ្តាលប្រវែង ៩គ.ម។
- ផ្លូវក្រវ៉ាត់ក្រុងទី៣ មានប្រវែង ៥៣គម មាន ៤ គន្លង ប្រភេទផ្លូវបេតុងអាមេ តភ្ជាប់ពីផ្លូវជាតិលេខ៤ ទៅកាន់ផ្លូវជាតិលេខ១។
- ការជួសជុលស្តារឡើងវិញផ្លូវជាតិលេខ៣ មានប្រវែង ១៣៤គីឡូម៉ែត្រ ៨២៦ម៉ែត្រ ឆ្លងកាត់ខេត្តកណ្តាល ប្រវែង ១១គ.ម។
- ជួសជុលស្តារឡើងវិញផ្លូវជាតិលេខ២ មានប្រវែងជាង ៦៣គីឡូម៉ែត្រ ចាប់ពីរង្វង់មូលតាខ្មៅ(ខេត្តកណ្តាល) ដល់អូរចំបក(ខេត្តតាកែវ) មាន ៤គន្លង ក្រាលបេតុងកៅស៊ូ (AC) ឆ្លងកាត់ខេត្តកណ្តាល ប្រវែង ១៤,២១គ.ម។
- ជួសជុលស្ពានកាត់ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវក្នុងក្រុងតាខ្មៅ ចំនួន ៣២ខ្សែ ប្រវែងសរុប ១២៩គីឡូម៉ែត្រ និង៥៦៣ម៉ែត្រ មានប្រភេទក្រាលកៅស៊ូ AC និងDBST, ប្រភេទផ្លូវបេតុង និងប្រភេទផ្លូវក្រួសក្រហម។
- និងជាពិសេស អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ ខ្នាត4F អាចទទួលអ្នកដំណើរបានជាង ១៥លាននាក់ ក្នុង១ឆ្នាំ នៅឆ្នាំ២០៣០ អាចទទួលបានអ្នកដំណើររហូតដល់ ៣០លាននាក់ ក្នុង១ឆ្នាំ នៅឆ្នាំ២០៥០ និងនៅពេលបញ្ចប់ការសាងសង់ទាំងស្រុង ព្រលានយន្តហោះនេះ នឹងអាចទទួលអ្នកដំណើរបានប្រមាណ ៤៥លាននាក់ ក្នុង១ឆ្នាំ ចាប់ពីឆ្នាំ២០៥០។

## 6) <u>វិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី</u>

ក្នុងគោលបំណងធានាដល់ការប្រើប្រាស់ដី ប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការការពារធនធានធម្មជាតិ ព្រៃឈើ បឹងធម្ម

ជាតិ រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់អនុវត្តគោលនយោបាយរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

**ក) ការបញ្ចប់ការកែសម្រួលប្លង់ហេដ្ឋារចនាសម្ព័ន្ធទូទាំងខេត្តកណ្តាល (បានបញ្ចប់ទាំងស្រុង នៅខែឧសភា ២០២២) ៖** ប្លង់ហេដ្ឋារចនាសម្ព័ន្ធ(ផ្លូវ) សរុបមានចំនួន ១៣,៣៩៦ ខ្សែ ត្រូវបានរៀបចំកែសម្រួលឡើងវិញ ក្នុងនោះ ៖ ផ្លូវលុបមានចំនួន ៣,៤០៦ ខ្សែ ស្មើនឹង ២៦,៩៨%, ផ្លូវពង្រីកមានចំនួន ១៤៦ខ្សែ ស្មើនឹង ១.១៦%, ផ្លូវបង្រួមមានចំនួន ៤,៨១៤ខ្សែ ស្មើនឹង ៣៨.១៣%, ផ្លូវបង្កើតថ្មីមានចំនួន ១,១៧៧ខ្សែ ស្មើនឹង ៩.៣២%, និង ផ្លូវរក្សាទុកទំហំដដែល មានចំនួន ៣,៨៥៣ខ្សែ ស្មើនឹង ៣០.៥២%។

**ខ) ការងារគ្រប់គ្រងដីធ្លី ៖**

- ការចុះបញ្ជីដីរដ្ឋ៖ ចុះបញ្ជីដីរដ្ឋ បានចំនួន ២៤១ ទីតាំង ទំហំ ១២,៤៤៦ ហិកតា, កំពុងអនុវត្តនីតិវិធី ចំនួន ៦៦ ទីតាំង និងមិនទាន់អនុវត្តនីតិវិធី ចំនួន ៦ ទីតាំង។
- ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ បានចំនួន ១៨៣,៥០៣ ប័ណ្ណ។
- ការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធទូទាំងខេត្ត ជូនប្រជាពលរដ្ឋ៖
  + បានចុះបញ្ជីចប់ ចំនួន ៤៩ ឃុំ/សង្កាត់ លើ ១២៧ ឃុំ/សង្កាត់ ស្មើនឹង ៤៣១ ភូមិ ស្មើនឹង ៤២,៧ % គិតជាប័ណ្ណ បានចំនួន ៣៣០,៦៨៨ ប័ណ្ណ ក្នុងនោះ ក្រុងតាខ្មៅ និងស្រុកកណ្តាលស្ទឹង បានចុះបញ្ជីចប់ជាស្ថាពរ។
  + កំពុងអនុវត្តចុះបញ្ជីចំនួន ៥០ ឃុំ / ១២៧ ឃុំ/សង្កាត់ ចំនួន ៣៩០ ភូមិ ស្មើនឹង ៣៨,៦%។
  + មិនទាន់បានចុះបញ្ជី ចំនួន ២៨ ឃុំ / ១២៧ ឃុំ/សង្កាត់ ចំនួន ១៨៩ ភូមិ ស្មើនឹង ១៨,៧ %។

❖ បច្ចុប្បន្ន រដ្ឋបាលខេត្តកណ្តាល កំពុងអនុវត្តយុទ្ធនាការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធទូទាំងខេត្តដោយគ្រោងនឹងបញ្ចប់ការប្រកាសតំបន់វិនិច្ឆ័យទាំងស្រុង នៅត្រឹមដំណាច់ខែ មេសា ឆ្នាំ២០២៣។

**គ) វិស័យសំណង់** ៖ គិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ មានចំនួនសរុប ៣១៣ គម្រោង ស្មើនឹងទំហំ ២,៧៦៣,៨០៥ ម៉ែត្រការ៉េ ទុនវិនិយោគសរុបចំនួន ៧៨៦,៥៧២,៥៣៨ ដុល្លារ។

**7) <u>ការងារដោះស្រាយក្រៅប្រព័ន្ធតុលាការ</u> ៖**

រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់ដោះស្រាយសំណើ សំណូមពរ និងការស្នើសុំជួយអន្តរាគមន៍នានារបស់ប្រជាពលរដ្ឋ ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

**ក).ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ៖** ករណីដីធ្លីដែលទទួលបានការស្នើសុំរបស់ប្រជាពលរដ្ឋ ខេត្តបានយកចិត្តទុកដាក់ធ្វើការពិនិត្យសិក្សាស្រាវជ្រាវ និងដោះស្រាយដោយគិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ មានចំនួន ៣៤៤ករណី ក្នុងនោះ បានដោះស្រាយបញ្ចប់ចំនួន ២១៨ករណី និងបន្តសិក្សាស្រាវជ្រាវចំនួន ១២៦ករណី។

**ខ). ការឆ្លើយតបក្រសួងមហាផ្ទៃ ពាក់ព័ន្ធនឹងការចុះផ្សាយរបស់សារព័ត៌មាន និងការខមមិនចូលផេករបស់សម្តេចក្រឡាហោម៖** គិតចាប់តាំងពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២២ មានចំនួនសរុប ១៣០ករណី ក្នុងនោះ ករណីបានឆ្លើយតបរួច ចំនួន ១១២ករណី និងករណីបន្តដោះស្រាយ ចំនួន ១៨ករណី។

## ៨) <u>វិស័យការងារ បណ្តុះបណ្តាល និងវិជ្ជាជីវៈ</u>

អនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិដ៏ជាក់លាក់របស់រាជរដ្ឋាភិបាល ក្នុងការជំរុញឱ្យប្រជាពលរដ្ឋមានការងារសមរម្យ និងកម្រិតជីវភាពកាន់តែប្រសើរឡើង, លើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ, បង្កើនបាននូវកម្លាំងពលកម្ម ឬធនធានមនុស្សប្រកបដោយចំណេះដឹងសមត្ថភាព ជំនាញឥរិយាបថការងារ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត និងធានាថា ប្រជាពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់អនុវត្តគោលនយោបាយ និងសម្របសម្រួលការអនុវត្តលក្ខខណ្ឌការងារបានល្អប្រសើរ ដែលទាក់ទាញការវិនិយោគ ដោយបច្ចុប្បន្នខេត្តកណ្តាលមាន រោងចក្រ សហគ្រាសចំនួន ៤៨៣ កម្មករនិយោជិត ១៥៣,៤០៥នាក់ (ស្រី ១២០,២០៦នាក់) ក្នុងនោះមានរោងចក្រកាត់ដេរ សម្លៀកបំពាក់ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ-កាបូប មានចំនួន ១៧១ទីតាំង មានកម្មករនិយោជិត ១៣២,៥៨៧នាក់ (ស្រី ១១០,១១១នាក់)។ ចំណូលទទួលបានពីវិស័យការងារ ក្នុងមួយខែ បានចំនួន ៣៦លាន ១៩៣ពាន់ ៧៩៤ ដុល្លារ (សាមសិបប្រាំមួយលាន មួយរយកៅសិបបីពាន់ប្រាំពីរយកៅសិបបួនដុល្លារគត់) និងក្នុងមួយឆ្នាំ បានប្រហាក់ប្រហែលចំនួន ៤៣៤លាន ៣២៥ពាន់ ៥២៨ ដុល្លារ។

ខេត្តកណ្តាល ក៏មានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងក្រុងតាខ្មៅ ក្នុងការជួយបំប៉នសមត្ថភាព តម្រង់ទិសដល់ប្រជាពលរដ្ឋ ដើម្បីអាចឈានជើងចូលទីផ្សារការងារ ដោយបានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ចំនួន ០៧ រួមមាន៖ ជំនាញអគ្គិសនី, បរិក្ខារម៉ាស៊ីនត្រជាក់, សំណង់ស៊ីវិល, ព័ត៌មានវិទ្យា, ជំនាញជួសជុលរថយន្ត, ជំនាញបស្សុ

ពេទ្យ, ជំនាញភាសាអង់គ្លេស ដែលគិតមកទល់ពេលនេះ សិស្សដែលបានបញ្ចប់ការសិក្សាមានចំនួន ២៣០នាក់ (ស្រី៤៤នាក់) ហើយក្នុងឆ្នាំសិក្សាថ្មីនេះ ២០២២-២០២៣ កំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររង ចំនួន ២៤៤នាក់ (ស្រី៦៥នាក់) រយៈពេល២ឆ្នាំផងដែរ។

ទន្ទឹមនឹងការគិតគូអភិវឌ្ឍទីផ្សារការងារដែលមានភាពធន់ ផ្តល់ប្រាក់ចំណូលខ្ពស់សម្រាប់ប្រជាពលរដ្ឋ រដ្ឋបាលខេត្តក៏បានយកចិត្តទុកដាក់អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគិតគូអំពីសុខុមាលភាពកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធតាមរយៈការផ្តល់នូវរបបសន្តិសុខសង្គម (ប.ស.ស) ដែលបានពង្រីកវិសាលភាពដែលមានស្រាប់ បង្កើនការគាំពារដល់បងប្អូនកម្មករនិយោជិតគ្រប់រូប ទាំងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធរួមជាមួយគោលនយោបាយផ្តល់ប្រាក់សោធននិវត្តន៍សម្រាប់កម្មករនិយោជិត ដែលបម្រើការនៅក្នុងវិស័យឯកជន គឺជាសមិទ្ធផលដ៏ធំធេងមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ សាខាបេឡាជាតិសន្តិសុខសង្គមខេត្តកណ្តាល បានអនុវត្តការងារដូចខាងក្រោម ៖

- ការងារបង់ភាគទាន ៖
  - ផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិតមានចំនួន ១៤២,៤៦២ នាក់
  - ផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតមានចំនួន ១៤២,៤៦២
  - កម្មករនិយោជិតក្រៅប្រព័ន្ធមានចំនួន ៦២៣នាក់ ស្រី ៧៧នាក់
- ចំពោះផ្នែកថែទាំសុខភាព ៖
  - មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ៖ ប្រើប្រាស់សេវាក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស.ចំនួន១០,៣៥៥ នាក់
  - កម្មករនិយោជិត ៖
    - ប្រើប្រាស់សេវាថែទាំសុខភាពជាមួយមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ចំនួន ១៣១,៤៤១ នាក់
    - ចូលប្រើប្រាស់សេវាហានិភ័យការងារជាមួយមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ចំនួន ៣៣,៧៤៣ នាក់
    - បានផ្តល់ប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាលសម្រាប់កម្មករជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធនៅពេលសម្រាលកូន ចំនួន ៦,៩៤២នាក់ មានទឹកប្រាក់ចំនួន ២ប៊ីលាន ៧៧៨លាន ៤០០ពាន់រៀល។

▪ ប្រាក់បំណាច់លំហែមាតុភាពចំនួន ៣៩,៦៨៤ នាក់

ជាមួយគ្នានេះ រដ្ឋបាលខេត្ត ក៏បានបង្ហាញពីការយកចិត្តទុកដាក់ និងការផ្សារភ្ជាប់មនោសញ្ចេតនា ដើម្បីភ្ជាប់ជាប់នូវសុខទុក្ខ ជីវភាពរស់នៅប្រចាំថ្ងៃ ជាមួយបងប្អូនបម្រើការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាអ្នករត់ម៉ូតូកង់បី, រ៉ឺម៉ក ជាដើម។ ជាក់ស្ដែងកាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០២៣ រដ្ឋបាលខេត្ត បានរៀបចំពិធីសំណេះសំណាលជាមួយគ្គលិកនារីបម្រើការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្នែកសេវាកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ចំនួន ១,១៧៨នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

9) **<u>អំពីការងារសុខាភិបាល</u> ៖**

ខេត្តមានមូលដ្ឋានសុខាភិបាលចំនួន ១២០កន្លែង សម្រាប់ផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ក្នុងនោះមាន មន្ទីរពេទ្យបង្អែក ១១កន្លែង, មណ្ឌលសុខភាព ១០៦កន្លែង និង ប៉ុស្តិ៍សុខភាព ៣កន្លែង និងឡប្រព្រឹត្តកម្មសំណល់វេជ្ជសាស្ត្រចំនួន ១កន្លែង ក្នុងស្រុកអង្គស្នួល ដែលត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីខែមិថុនា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក។

ចំពោះការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ខ្ញុំសូមគោរពថ្លែងអំណរគុណដល់ក្រុមគ្រូពេទ្យបុគ្គលិកសុខាភិបាលគ្រប់លំដាប់ថ្នាក់ក្នុងខេត្តកណ្តាល, សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ(TYDA), ក្រុមគ្រូពេទ្យក្រសួងការពារជាតិ, ក្រុមគ្រូពេទ្យស្ម័គ្រចិត្តឯកឧត្តម ហ៊ុន ម៉ានី ដែលបានសាមគ្គីជាធ្លុងមួយអនុវត្តបានដោយជោគជ័យនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋក្នុងខេត្តកណ្តាល ដែលគិតត្រឹមថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២៣ ការចាក់វ៉ាក់សាំង បានលើសផែនការគ្រោងទុក ក្នុងនោះ ៖

- ការចាក់ដូសមូលដ្ឋាន ដូសទី១ និងដូសទី២ សម្រេចបាន ១០៧%
- ដូសទី៣ សម្រេចបាន ៩៦%, ដូសទី៤ សម្រេចបាន ៣៧%, ដូសទី៥ សម្រេចបាន ១៤% និងដូសទី៦ សម្រេចបាន 0.៦០%។

នៅក្នុងឱកាសនេះផងដែរ ខ្ញុំក៏សូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល, ឯកឧត្តម ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក, សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាលគ្រប់លំដាប់ថ្នាក់ ដែលជានិច្ចជាកាលតែងតែបានជួយឧបត្ថម្ភ គាំទ្រ ទាំងស្មារតី និងសំភារៈ នៅគ្រប់កាលៈទេសៈ និងតែងនៅកៀកជាប់ ដោះស្រាយបញ្ហា ការលំបាករបស់ប្រជាពលរដ្ឋ

នៅមូលដ្ឋាន។ ជាពិសេសនៅក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់ថ្នាក់ បានជួយឧបត្ថម្ភគាំទ្រដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដោយបានឧបត្ថម្ភជាថវិកា គ្រឿងឧបភោគបរិភោគ ថ្នាំពេទ្យ សម្ភារៈប្រើប្រាស់ រថយន្តសង្គ្រោះបន្ទាន់ និងសម្ភារៈបរិក្ខារសុខាភិបាលជាច្រើនផងដែរ។

## 10) <u>ការគាំពារសង្គម</u> ៖

ទន្ទឹមនឹងការជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋពីជំងឺកូវីដ-១៩ តាមរយៈការចាក់វ៉ាក់សាំងស្រោចជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលក៏បានគិតគូប្រកបដោយភាពបុរេសកម្ម ក្នុងការឆ្លើយតប ការកាត់បន្ថយផលប៉ះពាល់សង្គម-សេដ្ឋកិច្ចឱ្យស្ថិតក្នុងកម្រិតអប្បបរមា តាមរយៈការដាក់ចេញវិធានការអន្តរាគមន៍ជាបន្តបន្ទាប់ និងទាន់ពេលវេលា ប្រកបដោយភាពម្ចាស់ការ ជាពិសេសការដាក់ចេញនូវកម្មវិធីគាំពារសង្គមនានា មានដូចជា ៖ "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ", "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩", "កម្មវិធីជំនួយសង្គមក្រោយពេលបិទខ្ទប់សម្រាប់គ្រួសារ ប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព គ្រួសារឆ្លងជំងឺកូវីដ-១៩ និងគ្រួសារដែលមានអ្នកស្លាប់ដោយជំងឺកូវីដ-១៩, "ជំនួយឧបត្ថម្ភសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់" និង "គ្រួសារងាយរងហានិភ័យក្នុងកំឡុងពេលមានអតិផរណា" ដែលគិតមកទល់ពេលនេះ ប្រជាពលរដ្ឋក្នុងខេត្តកណ្តាល ចំនួន ៧៥,៩៨៧ គ្រួសារ កំពុងទទួលផលពីកម្មវិធីជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដែលមានទឹកប្រាក់ ២០៦ប៊ីលាន ៨៣៥លាន ៦៩៦ពាន់ ៩០០រៀល ប្រហាក់ប្រហែល ៥១,៧៤៤,៩៦៧ ដុល្លារ។

## 11)<u>អំពីវិស័យកសិកម្ម</u>

រដ្ឋបាលខេត្ត អនុវត្តតាមយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍កសិកម្ម បានកំណត់ចក្ខុវិស័យច្បាស់លាស់ក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម ឱ្យកាន់តែមានភាពប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ មាននិរន្តរភាព និងកាត់បន្ថយថ្លៃដើមផលិតកម្ម តាមរយៈការផ្តល់នូវបច្ចេកទេសជូនដល់កសិករ ដែលនឹងធ្វើឲ្យកើនឡើងនៃប្រាក់ចំណូលគ្រួសារកសិករ ប្រកបដោយវិបុលភាព និងសុខមាលភាព ព្រមទាំងមានគោលដៅធ្វើពិពិធកម្មវិស័យកសិកម្មខេត្ត ទៅជាកសិ-ទេសចរ និងកសិ-ឧស្សាហកម្ម ។

អាស្រ័យដោយពិនិត្យឃើញអំពីសក្តានុពលរបស់ខេត្តលើការដាំដុះបន្លែគ្រប់មុខ រដ្ឋបាលខេត្ត មានមហិច្ឆតាសម្រេចឱ្យបានជាខេត្តលំដាប់ថ្នាក់ទី១ក្នុងចំណោម ២៥រាជធានី/

ខេត្ត ដែលមានការនាំចេញបន្លែទៅលក់នៅលើទីផ្សារច្រើនជាងគេ។ ដើម្បីសម្រេចបានគោលដៅនេះ រដ្ឋបាលខេត្ត បានដាក់ចេញផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍមាសបៃតងខេត្តកណ្តាល (២០២៣-២០៣០)ដែលជាត្រីវិស័យសម្រាប់ផលិតកម្មបន្លែ និងផ្លែឈើប្រកបសុវត្ថិភាព និងគុណភាព។ ខេត្តបានចងក្រងបណ្តុំអាជីវកម្មបន្លែសុវត្ថិភាពបានចំនួន ៧៥ បណ្តុំ និងបណ្តុះបណ្តាលសមាជិកបណ្តុំបាន ៣,៥៣២នាក់ ក្នុងនោះទទួលបានវិញ្ញាបនបត្រចំនួន ៤៥ នាក់។ ការដាំបន្លែប្រភេទផ្ទះសំណាញ់ មានចំនួន ១៨៩ខ្នង អាចផលិតបន្លែក្នុងបរិមាណ ៦៨តោន/១ថ្ងៃ។

ជាមួយគ្នានេះ ខេត្តកណ្តាល ដោយមានជំនួយឥតសំណង របស់រាជរដ្ឋាភិបាលជប៉ុនដែលបានជួយឧបត្ថម្ភថវិកា និងបច្ចេកទេស ខេត្តមានមជ្ឈមណ្ឌលប្រមូលផ្តុំ ត្រួតពិនិត្យគុណភាព និងចែកចាយបន្លែសុវត្ថិភាព ជាមជ្ឈមណ្ឌលតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលមានស្តង់ដារបច្ចេកទេស ក្នុងការត្រួតពិនិត្យ និងបញ្ជាក់គុណភាពបន្លែ ផ្លែឈើ មុននាំទៅលក់លើទីផ្សារ ដែលមានសេវាលាងសម្អាត វេចខ្ចប់ ត្រួតពិនិត្យ និងធ្វើតេស្ត រកសារជាតុពុលបន្សល់ក្នុងបន្លែ និងផ្លែឈើ ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ភាពខ្លាំងរបស់ខេត្តក្នុងផលិតកម្មបន្លែ ផ្លែឈើ មិនត្រឹមតែអាចប្រកួតប្រជែងគុណភាព សុវត្ថិភាព លើទីផ្សារក្នុង និងក្រៅប្រទេសប៉ុណ្ណោះ ប៉ុន្តែអាចធានាបានសុខុមាលភាពអ្នកបរិភោគជាសាធារណៈទៀតផង។ បច្ចុប្បន្ន មជ្ឈមណ្ឌលបានវិភាគសំណាកបន្លែនិងផ្លែឈើសម្រេច បានចំនួន ១,៣០៤ សំណាក ក្នុងនោះពិនិត្យឃើញសារជាតុពុលបន្សល់ទុកលើសកម្រិតហាមឃាត់ចំនួន ៦០ សំណាក។

12) **<u>វិស័យអប់រំ យុវជន និងកីឡា</u>**

ការអភិវឌ្ឍធនធានមនុស្ស គឺជាគោលដៅអាទិភាពទី១ របស់រាជរដ្ឋាភិបាល ដែលផ្តល់ឱកាសស្មើៗគ្នាដល់យុវជនកម្ពុជាក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។

តាមរយៈកំណែទម្រង់ការប្រឡងសញ្ញាបត្រមធម្យសិក្សាទុតិយភូមិ ចាប់ពីឆ្នាំ២០១៤ តាមទិសស្លោក អ្នកចេះគឺជាប់ លទ្ធផលសិស្សក្នុងខេត្តកណ្តាលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានចាប់ផ្តើមពី ២៧.៥៧% ក្នុងឆ្នាំ២០១៤ បានកើនដល់ ៧៥.៩៥% នៅក្នុងឆ្នាំសិក្សា២០២១-២០២២ ក្នុងនោះ សិស្សនិទ្ទេស A សរុប១០៤នាក់, និទ្ទេស B ៦៩១នាក់, និទ្ទេស C សរុប ១,៧៦៧នាក់, និទ្ទេស D សរុប ២,៥០៥នាក់,និទ្ទេស E ២,៤៨២ នាក់ និងនិទ្ទេស F សរុប ២,៣៩០ នាក់ ស្រី ១,១៣០នាក់។

ខេត្ត ក៏មានសក្តានុពលធនធានមនុស្សក្នុងវិស័យកីឡាផងដែរ ដោយក្នុងការប្រកួតព្រឹត្តិការណ៍កីឡាជាតិលើកទី៣ និងកីឡាប៉ារ៉ាហ្គេមលើកទី១ ខេត្តកណ្តាល ទទួលបានចំណាត់ថ្នាក់លេខ៤ នៅទូទាំងប្រទេស ដែលទទួលបានមេដាយសរុបច្រើនជាងគេ។ ជាមួយ

គ្នានេះ ក្រុមកីឡាបាល់ទាត់បុរស និងនារី ស.ស.យ.ក ខេត្តកណ្ដាល ដែលបានចូលរួមប្រកួតដណ្ដើមពានរង្វាន់ Soccer League លើកទី៦ ដែលមានក្រុមកីឡាបាល់ទាត់ចូលរួមប្រកួត៧៤ក្រុមមកពីទូទាំងប្រទេស ក្នុងនោះ ក្រុមកីឡាបាល់ទាត់បុរស ស.ស.យ.ក ខេត្តកណ្ដាល ទទួលបានចំណាត់ថ្នាក់លេខ១ ជាម្ចាស់ពានរង្វាន់ Soccer League លើកទី៦ និងក្រុមកីឡាបាល់ទាត់នារី ស.ស.យ.ក ស្រុកស្អាងយើងស្អាត ទទួលបានចំណាត់ថ្នាក់លេខ៣ នៅទូទាំងប្រទេស។

ក្រៅពីការរៀបរាប់ខាងលើ ក៏នៅមានសមិទ្ធិផលសំខាន់ៗ និងពានរង្វាន់ជាច្រើន ដែលរដ្ឋបាលខេត្ត សម្រេច និងទទួលបាន ដូចខាងក្រោម ៖

➢ **សមិទ្ធិផលហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ៖**

- រោងចក្រផលិតអគ្គិសនីដើរដោយថាមពលប្រេងខ្មៅនិងឧស្ម័ន ៖ មានកម្លាំងអានុភាព ៤០០មេហ្គាវ៉ាត់ ស្ថិតនៅស្រុកល្វាឯម។
- មជ្ឈមណ្ឌលជាតិព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅស្រុកកណ្ដាលស្ទឹង។
- មជ្ឈមណ្ឌលព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនថ្នាំញៀន នៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល មានអគារសរុប ចំនួន ២១ អគារ ដែលបច្ចុប្បន្នអគារទាំងនោះដំណើរការសាងសង់សម្រេចបាន ៩៥ ភាគរយ។
- អគារវះកាត់ អគារសម្ភព អគារជំងឺឆ្លង និងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យបង្អែកជ័យជំនះក្រុងតាខ្មៅ។
- មន្ទីរពេទ្យ **"តេជោសែនកោះធំ"** ជាមន្ទីរពេទ្យស្រុកធំជាងគេនៅក្នុងប្រទេសកម្ពុជាគ្រោងដាក់ឱ្យដំណើរការនៅពេលខ្លីខាងមុខ។

➢ **ការទទួលបានពានរង្វាន់នានា ៖**

- បានទទួលជ័យលាភីទីក្រុងស្អាតផ្ការំដួល២ទង លើកទី២ ឆ្នាំ២០១៨ និងលើកទី៣ ឆ្នាំ២០២២សុពលភាព ២០២២-២០២៥។
- បានទទួលជ័យលាភីពានទីក្រុងទេសចរណ៍ស្អាតអាស៊ាន លើកទី២ ឆ្នាំ២០២០ (ទទួលនៅប្រទេសព្រុយណេ)។
- បានទទួលចំណាត់ថ្នាក់ជើងឯកលេខ ២ ពានរង្វាន់សេវាសង្គម ពីក្រសួងមហាផ្ទៃ
- បានទទួលជ័យលាភីលេខ៣ ជាការិយាល័យប្រជាពលរដ្ឋខេត្តឆ្នើម ប្រចាំឆ្នាំ ២០២២។

- ជាខេត្តទី៣ បានទទួលជ័យលាភី ក្នុងការបញ្ចប់បន្ទោបង់ពាសវាលពាសកាល ODF ពីក្រសួងអភិវឌ្ឍន៍ជនបទ (ប្រារព្ធពិធីប្រកាសជ័យលាភីផ្លូវការជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២)។
- ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ជាថ្នាក់ដឹកនាំកំពូលទី១លើពិភពលោក ដែលបានរំដោះផ្ទៃដីមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម បានធំជាងគេ និងបានប្រែក្លាយដីមីន ទៅជាដីមាស ខេត្តកណ្តាលត្រូវបានប្រកាសជាផ្លូវការ ជាខេត្តអត់មីន កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**។

ក្រៅពីសមិទ្ធផលដូចបានរៀបរាប់តាមបណ្តាវិស័យជំនាញខាងលើ រដ្ឋបាលខេត្ត ក៏នៅមានសមិទ្ធផលជោគជ័យជាច្រើនទៀតដែលសម្រេចបានក្នុងរយៈពេល៥ឆ្នាំកន្លងមក ដែលមិនអាចរៀបរាប់អស់នៅក្នុងរបាយការណ៍ ត្រឹមរយៈពេល៤០នាទីនេះឡើយ។ ភាពជោគជ័យទាំងអស់នេះ គឺអាស្រ័យបានមកពីការខិតខំសាមគ្គីរួមគ្នាជាធ្លុងមួយពីគ្រប់តួអង្គ អាជ្ញាធរ ក្រុមការងាររាជរដ្ឋាភិបាល ដែលបានខិតខំរួមគ្នាធ្វើ ដោះស្រាយបញ្ហាប្រឈម ដើម្បីភាពសុខដុមរមនា និងវិបុលភាព ជូនប្រជាពលរដ្ឋ ដោយបានយកបេះដូងរបស់ខ្លួនជាអ្នកបម្រើប្រជាពលរដ្ឋ ទៅដាក់ជាប់និងប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

- បន្តពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ-សង្កាត់ មានសុវត្ថិភាព ដើម្បីការពារនូវសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់សាធារណៈ និងសុវត្ថិភាពសង្គម។ ជាពិសេសការចេញនូវទិសដៅការងារអាទិភាពក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យអស់ពីសហគមន៍ ដោយអនុវត្តតាមទិសស្លោក "៣កុំ ១រាយការណ៍"។
- ជម្រុញការប្រឡងចំណាត់ថ្នាក់ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ឃុំ សង្កាត់ទាំងអស់មិនមានចំណាត់ថ្នាក់លេខ២ និងលេខ៣ គឺមានតែចំណាត់ថ្នាក់លេខ១។
- បង្កើនការផ្សព្វផ្សាយ ទប់ស្កាត់ បង្ក្រាប បទល្មើស ការជួញដូរមនុស្សគ្រប់ទម្រង់, ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ, បទល្មើសគេចពន្ធ, ទប់ស្កាត់ប្រឆាំងបទល្មើសសំអាតប្រាក់។
- បន្តអនុវត្តកំណែទម្រង់ស៊ីជម្រៅឱ្យបានជាប់ជានិច្ច នូវបាវចនា២ និងអភិក្រម៥ ដែលបានដាក់ចេញដោយ សម្តេចតេជោនាយករដ្ឋមន្ត្រី គឺ៖ បាវចនា២ "កែទម្រង់

ខាងក្នុង និងបង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ" និងអភិក្រមទាំង៥ "ឆ្លុះ កញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"។

- បន្តពិនិត្យ និងជំរុញការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋគ្រប់អាយុត្រូវផ្តល់ អ្នកមិនទាន់បានផ្តល់ អ្នកបាត់ ខូច និងហួសសុពលភាព សម្រាប់បម្រើឱ្យការងារបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៧។
- បង្កើនកិច្ចការដឹកនាំសហការសម្របសម្រួលជាមួយកងកម្លាំងមានសមត្ថកិច្ចដែលឈរជើងនៅតាមតំបន់ ព្រំដែនគ្រប់ថ្នាក់ ដើម្បីថែរក្សា និងការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិ និងពង្រឹងការគ្រប់គ្រងការចេញចូលឆ្លងព្រំដែន ទាំងមនុស្ស និងទំនិញ។
- ត្រៀមសហការជាមួយគណៈកម្មការអន្តរក្រសួងក្នុងការសាងសង់ច្រាំងដែលមានលក្ខណៈរឹងមាំយូរអង្វែង នៅទន្លេបាសាក់ និងព្រែកជ្រៃធំ តាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម និងការដោះស្រាយបញ្ហាបាក់ច្រាំងទន្លេតាមបណ្តាក្រុងស្រុក។
- ជំរុញការងារបង្កបង្កើនផលស្រូវ គ្រប់រដូវ និងធ្វើពិពិធកម្មកសិកម្ម ការចិញ្ចឹមសត្វជាពិសេសការអនុវត្តតាមផែនការអភិវឌ្ឍមាសបៃតងរបស់ខេត្ត។
- ជំរុញការដាំដើមឈើគ្រប់ប្រភេទតាមផែនការគ្រោងទុក នៅតាមផ្លូវសាធារណៈក្នុងមូលដ្ឋាន ដើម្បីប្រែក្លាយមុខមាត់ខេត្ត ជាខេត្តមានបរិស្ថានធម្មជាតិ និងមានសម្រស់ដោយរុក្ខជាតិបៃតងនៅគ្រប់ទីកន្លែង និងឈានដល់ការបង្កើតឱ្យមានឧទ្យានធម្មជាតិតាមបណ្តាក្រុងស្រុក។
- បន្តសិក្សាលទ្ធភាពតបណ្តាញទឹកស្អាតចំនួន ៦៥ភូមិបន្តទៀត។
- សិក្សាលទ្ធភាពតបណ្តាញអគ្គិសនីជូនប្រជាពលរដ្ឋឱ្យបានគ្រប់ខ្នងផ្ទះ។
- ខិតខំសហការដោះស្រាយសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋ ឱ្យបានសមស្រប និងទាន់ពេលវេលា។
- បន្តលើកកម្ពស់សមត្ថភាពមន្ត្រីក្នុងការផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- បន្តជំរុញប្រជាពលរដ្ឋឱ្យទៅចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសជម្រុញតាមកាលកំណត់ នៃផែនការរបស់រាជរដ្ឋាភិបាល។
- បន្តតាមដាន ពិនិត្យ ជំរុញការឆ្លើយតបលិខិតរបស់ក្រសួងមហាផ្ទៃ និងពិនិត្យដោះស្រាយរាល់សំណូមពរ របស់ប្រជាពលរដ្ឋបានComment និងផ្ញើទៅកាន់Facebook Page ថ្នាក់ដឹកនាំ។

- បន្តស្រាវជ្រាវ ដោះស្រាយ ករណីវិវាទដីធ្លីនៅមូលដ្ឋាន និងជំរុញការចុះបញ្ជីជាប្រព័ន្ធ និងការចុះបញ្ជីដីរដ្ឋ ដើម្បីកាត់បន្ថយទំនាស់ និងគ្រប់គ្រងឲ្យបានច្បាស់លាស់។

ជាមួយនឹងសមិទ្ធផលដែលរដ្ឋបាលខេត្តសម្រេចបាន រួមនិងទិសដៅការងារបន្តដែលរដ្ឋបាលខេត្តបានដាក់ចេញ ខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា សម្ដេច ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាពិសេសប្រជាពលរដ្ឋក្នុងខេត្តកណ្ដាលផ្ទាល់នឹងបន្តគាំទ្រដល់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក ពិសេសលោក លោកស្រី មេឃុំ ចៅសង្កាត់ និងថ្នាក់ភូមិ ដែលជាប្រតិបត្តិករអនុវត្តការងារ និងមានគណនេយ្យភាព ការទទួលខុសត្រូវជាមួយប្រជាពលរដ្ឋផ្ទាល់នៅមូលដ្ឋាន ដើម្បីដោះស្រាយបាននូវរាល់បញ្ហាប្រឈមដែលកើតមាន និងជួយតម្រង់ទិសក្នុងការអនុវត្តផែនការទិសដៅការងារចម្បងៗ របស់រដ្ឋបាលខេត្ត សំដៅចូលរួមអនុវត្តដោយជោគជ័យនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ពិសេស បន្តពង្រឹងការប្ដេជ្ញាចិត្តរួមគ្នាបន្តថែរក្សាការពារឱ្យបាននូវសុខសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គម ខិតខំរួមគ្នាធានាឱ្យការបោះឆ្នោតជាតិលើកទី៧ ប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ មានសុវត្ថិភាពយ៉ាងល្អប្រសើរ ព្រមទាំងចូលរួមរក្សាសុវត្ថិភាពឱ្យបានទាំងស្រុងនូវព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅកម្ពុជា ដែលនៅសល់តែ ៣៦ថ្ងៃទៀតប៉ុណ្ណោះ ប្រទេសកម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ដែលជាការប្រកួតកម្រិតអន្តរជាតិដ៏ធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយនេះនឹងក្លាយជាកិត្តិយសជាប្រវត្តិសាស្ត្រមួយទៀត ក្នុងវិស័យកីឡាដែលកម្ពុជារង់ចាំធ្វើជាម្ចាស់ផ្ទះអស់រយៈពេល ៦៤ ឆ្នាំមកហើយ។

សន្តិភាព និងវិបុលភាពសង្គម ដែលកំពុងតែផ្ដល់មនុញ្ញផលដល់ប្រជាជនកម្ពុជាទាំងអស់គ្នានាពេលបច្ចុប្បន្ន បានធ្វើឱ្យយើងមានមោទនភាពជាតិក្រៃលែង និងមានការជឿជាក់កាន់តែរឹងមាំថា ខ្មែរពិតជាអាចធ្វើបាន ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ ប៉ិនស្រប់ និងគតិបណ្ឌិតរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ដែលនេះគឺពិតជាស័ក្ដសមជាទីបំផុតដែល **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ជាទីគោរពស្រឡាញ់នៃយើង ទទួលបានពានរង្វាន់ **"សមិទ្ធផលពេញមួយជីវិតរបស់មេដឹកនាំឆ្នើមពិភពលោក"** ពីវិទ្យាស្ថានយុទ្ធសាស្ត្រសម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក(KSI) កាលពីខែធ្នូ ឆ្នាំ២០២២។

យើងទាំងអស់គ្នា ពិតជាមិនអាចអត់ឱនឱ្យបានឡើយចំពោះជនអគតិទាំងឡាយ ដែលរមិលគុណ តែងតែបានបំភ្លៃបំផ្លើស និងបំផ្លាញនូវសច្ចធម៌ប្រវត្តិសាស្ត្រជាតិ ហើយសូមគាំទ្រយ៉ាងម៉ឺងម៉ាត់បំផុតចំពោះការកម្ចាត់ចោល នយោបាយជ្រុលនិយមរបស់ទណ្ឌិតក្បត់ជាតិ និងបក្សពួក ដែលនឹងនាំទៅដល់គ្រោះមហន្តរាយជាថ្មីទៀតសម្រាប់ប្រជាជាតិខ្មែរយើង។ យើងមិនត្រូវបណ្តោយឱ្យស្នាមប្រវត្តិសាស្ត្រដ៏គ្រោះថ្នាក់របស់កម្ពុជាវិលមកជាន់ដានជាថ្មីម្តងទៀតជាដាច់ខាត។

ប្តេជ្ញាចូលរួមការពារ អង្គព្រះមហាក្សត្រ ការពាររាជរដ្ឋាភិបាលស្របច្បាប់!

ប្តេជ្ញា ការពារឯករាជ្យ អធិបតេយ្យភាពជាតិ ការពារសន្តិភាព ស្ថិរភាព ឱ្យបានដាច់ខាត

*ជយោ! សន្តិភាព និងការអភិវឌ្ឍ!*

*ជយោ ! ស្ថាបនិកអគ្គមគ្គុទេសន៍ឯក នយោបាយឈ្នះ-ឈ្នះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី!*

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមលើកហត្ថប្រួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយអភិបាលប្រោះព្រំ ប្រសិទ្ធពរជ័យជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និងអង្គសន្និសីទទាំងមូល សូមបានប្រកបនូវសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ និងសូមបានប្រកបនូវពុទ្ធពរជ័យទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមគោរពអរគុណ!